**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# របាយការណ៍

## កិច្ចប្រជុំប្រចាំត្រីមាសក្រុមការងារថ្នាក់ក្រោមជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍

**ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៦**

**នៅសណ្ឋាគារ សោមាទេវី ខេត្តសៀមរាប**

### ១. សេចក្តីផ្តើម:

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ដែលមានក្រុមការងារលេខាធិកាដ្ឋានបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ សហការជាមួយអង្គការសុខភាពបុរសកម្ពុជា បានរៀបចំកិច្ចប្រជុំប្រចាំត្រីមាសនៃក្រុមការងារថ្នាក់ក្រោមជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ នៅព្រឹកថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៦ ក្រោមការដឹកនាំ និងសម្របសម្រួល ឯកឧត្តមវេជ្ជ. តែង គន្ធី អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៅសណ្ឋាគារសោមាទេវី ខេត្តសៀមរាប ដោយមានការអញ្ជើញចូលរួមពីសមាជិកក្រុមការងារបច្ចេកទេសថ្នាក់ជាតិ អាជ្ញាធរមូលដ្ឋាន នគរបាល មន្រ្តីលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត អង្គការដែលធ្វើការជាមួយក្រុមប្រឈមមុខខ្ពស់ និងក្រុមគោលដៅគ្រួសារអាណាព្យាបាល ដែលអញ្ជើញមកពីខេត្តសៀមរាប។

### ២. គោលបំណងនៃកិច្ចប្រជុំ

-ពិនិត្យមើលភាពជោគជ័យ និងឧបសគ្គក្នុងការចូលរួមបទអន្តរាគមន៍បង្ការលើក្រុមស្រីស្រស់នៅខេត្តសៀមរាប។

- បង្ហាញនូវបទពិសោធន៍ការផ្តល់សេវា និងកិច្ចសហការល្អៗរវាងអាជ្ញាធរមូលដ្ឋាន និង អង្គការដៃគូក្នុងខេត្តសៀមរាប។



សមាជិក សមាជិកាក្នុងកិច្ចប្រជុំប្រចាំត្រីមាសក្រុមការងារថ្នាក់ក្រោមជាតិ

## ៣. ដំណើរការ និងលទ្ធផលនៃកិច្ចប្រជុំ

ជាកិច្ចចាប់ផ្តើម **ឯកឧត្តម វេជ្ជបណ្ឌិត តែង គន្ធី** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានមានមតិស្វាគមន៍ និងថ្លែងអំណរគុណ ដល់សមាជិក សមាជិកា ដែលបានអញ្ជើញចូលរួមនាពេលនេះ ហើយ កិច្ចប្រជុំនឹងប្រព្រឹត្តទៅតាមរបៀបវារៈដែលបានគ្រោងទុក។

### ក. ចំណាប់អារម្មណ៍របស់លោកស្រី កុយ វិសាល អភិបាលរងក្រុងសៀមរាបៈ

បានជម្រាបជូនពីរបាយការណ៍សង្ខេបក្នុងកិច្ចសហការរវាងអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ ក្នុងខេត្តសៀមរាប ដូចខាងក្រោម៖

- បញ្ហាហិបសង្គ្រោះរបស់ក្រុមស្រីស្រស់ ដែលបច្ចុប្បន្ននេះមានហិបចំនួនបី ជាអំណោយរបស់ឯកឧត្តមអគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលមួយបានដាក់នៅទីតាំងមជ្ឈមណ្ឌលកំសាន្តរូស្វូណា និងពីរទៀតដាក់នៅក្លឹបអង្គការសុខភាពបុរសកម្ពុជា រងចាំសូមការអនុញ្ញាតិផ្តល់អនុសាសន៍ពីអង្គប្រជុំពេលនេះ គួរដាក់នៅកន្លែងណាចំពោះហិបពីរដែលដាក់នៅក្លឹបអង្គការសុខភាពបុរសកម្ពុជា។
- បញ្ហាការដាំកូនឈើ សាលាក្រុងសៀមរាបបានជួបពិភាក្សាជាមួយរដ្ឋបាលព្រៃឈើខេត្តក្នុងការសូមទីតាំងដាំ ខាងរដ្ឋបាលព្រៃឈើមិនអនុញ្ញាតិឲ្យដាំតាមផ្លូវសាធារណៈទៅតាមដែលយើងចង់ដាំបានទេ(កូនដើមគគីរ) យោងតាមការយកដីក្រុងសៀមរាប ទៅពិសោធន៍ តែអាចដាំបានតែកូនធ្នង់(ពិបាករក)។

**ខ. ចំណាប់អារម្មណ៍របស់លោកវេជ្ជ. ឡាន វណ្ណសេង នាយករងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើរស្បែក និងកាមរោគនៃក្រសួងសុខាភិបាលៈ**

បានជម្រាបជូនពីស្ថានភាពទូទៅនៃការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍នៅក្នុងប្រទេសកម្ពុជាៈ

- អត្រាប្រេវ៉ាឡង់មេរោគអេដស៍បច្ចុប្បន្នមាន០.៦% និងមានអត្រាប្រេវ៉ាឡង់មេរោគអេដស៍ខ្ពស់បំផុត២.០% នាឆ្នាំ១៩៩៧។
- ក្រុមប្រឈមមុខខ្ពស់បំផុត រួមមានស្ត្រីធ្វើការនៅតាមគ្រឹះស្ថានកំសាន្ត ដែលមានអត្រាប្រេវ៉ាឡង់មេរោគអេដស៍ចំនួន១៤% ចំពោះអ្នកដែលមានដៃគូច្រើន និងចំនួន៤% ចំពោះអ្នកមានដៃគូតិច ចំណែកក្រុមបុរសស្រឡាញ់បុរសមានអត្រាប្រេវ៉ាឡង់មេរោគអេដស៍ចំនួន២.៣% (២០១០) និងក្រុមស្រីស្រស់ តាមការសិក្សាថ្មីៗ(២០១៥) មានអត្រាប្រេវ៉ាឡង់មេរោគអេដស៍ចំនួន ៥.៩% ខ្ពស់ជាងឆ្នាំ២០១៤ ដែលមានចំនួន ៤.២% តែប៉ុណ្ណោះ។
- តាមការសិក្សាថ្មីៗនេះ ក៏បានបង្ហាញផងដែរថា ក្រុមស្រីស្រស់ ដែលមានដៃគូទៀងទាត់ ឬគូសង្សារកំណាន់ការប្រើប្រាស់ស្រោមអនាម័យមានការថយចុះមានត្រឹមតែ៣០%ប៉ុណ្ណោះ និងចំពោះអ្នកដែលមានដៃគូផ្សេងៗ ឬបានផលប្រយោជន៍ការប្រើប្រាស់ស្រោមអនាម័យមានចំនួនជាង៦០%។
- ដោយឡែកនៅខេត្តសៀមរាប មានស្ត្រីធ្វើការនៅតាមគ្រឹះស្ថានកំសាន្ត ជាង៥០០០នាក់ក្រោមការគ្រប់គ្រងរបស់អង្គការCWPD ក្រុមបុរសស្រឡាញ់បុរស មានចំនួន១១១១នាក់ទូទាំងប្រទេសមានចំនួនជាងបីម៉ឺននាក់និងស្រីស្រស់ ចំនួន៣១០នាក់ (ប្រហែល១០%) ទូទាំងប្រទេសមានចំនួនជាងបីពាន់នាក់។
- គួរឲ្យកត់សំគាល់ក្រុមមួយទៀតប្រឈមខ្លាំងបំផុតនោះ គឺក្រុមប្រើប្រាស់គ្រឿងញៀន ការប្រើប្រាស់ការចាក់មានតែនៅរាជធានីភ្នំពេញប៉ុណ្ណោះ ដោយមានអង្គការពីរដែលកំពង់តែធ្វើការជាមួយ(អង្គការកសាង និងមិត្តសម្លាញ់) ដែលមានអ្នកប្រើប្រាស់គ្រឿងញៀនដោយចាក់ចំនួន១៣០០នាក់ នៅទូទាំងប្រទេស។ ថ្មីៗនេះតាមរយៈការសិក្សារបស់ URC ប៉ាន់ប្រមាណអ្នកប្រើប្រាស់គ្រឿងញៀនចាក់នៅរាជធានីភ្នំពេញ ចំនួន១០៨០នាក់ និងនៅខេត្តសៀមរាប និងបាត់ដំបង មានចំនួនគួរឲ្យកត់សំគាល់។
- ក្រោមការសម្របសម្រួលពីអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ សហការជាមួយអង្គការជាដៃគូ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើរស្បែក និងកាមរោគ បានរៀបចំគម្រោងផែនការសកម្មភាព ដើម្បីឆ្លើយតបការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ជាយុទ្ធវិធីជំរុញខ្លាំងក្លាការងារបង្ការ ថែទាំ និងព្យាបាលបន្តដល់ក្រុមប្រឈមមុខខ្ពស់។



គណៈអធិបតីក្នុងកិច្ចប្រជុំ

គ. បទបង្ហាញពីវឌ្ឍនៈភាពបទអន្តរាគមន៍បង្ការមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងចំណោមក្រុមស្រីស្រស់ និងកិច្ចសហការរវាងអាជ្ញាធរជាមួយអ្នកពាក់ព័ន្ធ៖

**I.** ការស្វែងរកករណីថ្មីនៃអ្នកផ្ទុកមេរោគអេដស៍តាមរយៈមិត្តភក្តិ **(PDI+)**៖

- **(IBBS2014)**ការប៉ាន់ប្រមាណនៃចំនួនអ្នកផ្ទុកមេរោគអេដស៍នៅទូទាំងប្រទេសកម្ពុជាមានចំនួនប្រមាណ ៧៥.០០០នាក់។
- ប្រមាណជាង ១៥.០០០នាក់ បានរស់នៅជាមួយមេរោគអេដស៍ដោយមិនដឹងខ្លួន។
- តាមទិន្នន័យអង្គការខាណាឆ្នាំ២០១៥ បានបង្ហាញថា ការធ្វើតេស្តឈាមក្នុងចំណោមក្រុមគោលដៅមិនអាចសម្រេចទៅតាមសូចនាករនោះទេ។
- ជម្រុញការស្វែងរកករណីថ្មីតាមរយៈមិត្តភក្តិ នៅក្នុងចំណោមក្រុមប្រឈមមុខខ្ពស់ ដែលលាក់មុខ ពិបាកជួប និងមិនធ្លាប់បានធ្វើតេស្តឈាមរកមេរោគអេដស៍។
- ដើម្បីឲ្យពួកគេដឹងពីស្ថានភាពសុខភាពរបស់ខ្លួន និងទទួលបាន សេវាអប់រំ ការធ្វើតេស្តឈាម ថៃទាំ និងព្យាបាលទាន់ពេលវេលា។

- លទ្ធផលនៃការធ្វើតេស្តឈាម ធៀបនឹងការអប់រំតាមក្រុមគោលដៅ២០១៦៖




- របាយការណ៍ការស្វែងរកករណីថ្មីតាមរយៈការធ្វើតេស្តពីចុងម្រាមដៃជាមួយ PDI+ ចាប់ពី ថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៦ ដល់ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៦៖



- ចំនួនសរុបកំពុងទទួលការព្យាបាលតាមដំណាក់កាលក្នុងចំណោមក្រុមស្រីស្រស់មកដល់ឆ្នាំ២០១៦៖




**ឃ. បទបង្ហាញពីការផ្តល់សេវាសុខភាព និងកិច្ចសហការរវាងអង្គការថែទាំសុខភាពគ្រួសារកម្ពុជា និងអង្គការជាដៃគូ៖**

- **សកម្មភាពសំខាន់ៗ៖**
    - ការសិក្សាស្រាវជ្រាវស្តីពីសុខភាពអ្នកបំប្លែងភេទ
    - .សិក្ខាសាលាពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធដើម្បីបង្កើតសៀវភៅណែនាំសម្រាប់អ្នកផ្តល់សេវាថែទាំសុខភាពនៃអង្គការរ៉ាក់
    - .បណ្តុះបណ្តាលដល់អ្នកផ្តល់សេវាគ្លីនិករ៉ាក់ និងបុគ្គលិកគម្រោង
    - .សហការជាមួយអង្គការដៃគូ ដើម្បីបញ្ជូនអ្នកបំប្លែងភេទទៅទទួលសេវានៅគ្លីនិករ៉ាក់
    - .ផ្តល់សេវាកម្មគ្លីនិកដោយឥតគិតថ្លៃដល់អ្នកបំប្លែងភេទ
    - .ការបោះពុម្ពសម្ភារៈអប់រំ និងផ្សព្វផ្សាយនៅគ្លីនិករ៉ាក់
    - .រៀបចំវេទិកាអ្នកបំប្លែងភេទប្រចាំឆ្នាំ
    - .រៀបចំសិក្ខាសាលាស្តីពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រដល់អ្នកពាក់ព័ន្ធ
- **ការផ្តល់សេវាដល់អ្នកបំប្លែងភេទ៖**
    - កំណត់រោគសញ្ញានៃជំងឺកាមរោគ:
        - ការវិភាគដោយមន្ទីរពិសោធន៍

- ការវិភាគចង្កោមរោគសញ្ញា
- ការព្យាបាលនៃជំងឺកាមរោគ:
  - ព្យាបាលដោយការអប់រំទាក់ទងទៅនឹងចំណេះដឹងចំពោះការថែទាំខ្លួនប្រាណ
  - ព្យាបាលដោយថ្នាំ
  - ព្យាបាលដោយការវះកាត់
- តេស្តឈាមរកមេរោគអេដស៍:
  - ផ្តល់ការប្រឹក្សា ការផ្តល់អប់រំ មុន និងក្រោយការធ្វើតេស្តឈាម
  - ការធ្វើតេស្តឈាមរកមេរោគអេដស៍
- ពិនិត្យ និងព្យាបាលជំងឺទូទៅ:
  - រាគរូស ឈឺក្បាល ក្តៅខ្លួន ផ្តាសាយ
  - សំរាកមិនសូវលក់ ឈឺក្រពះ សើស្បែក ។ល។
- ពិនិត្យ និងព្យាបាលជំងឺដុះសាច់លើប្រដាប់បន្តពូជ (សិរមាន់)

- **លទ្ធផលសកម្មភាពការងារពីខែមករា ដល់ខែកក្កដា ឆ្នាំ២០១៦៖**
  - ផ្តល់ស្រោមអនាម័យ និងទឹករំអិលសម្រាប់៦គ្លីនិក:
    - ស្រោមអនាម័យ ចំនួន១១៨៨០
    - ទឹករំអិល ចំនួន១១៨៨០
  - ផ្តល់វគ្គបណ្តុះបណ្តាលស្តីពីការស្វែងយល់ពីតំរូវការរបស់អ្នកប្តូរយេនឌ័របញ្ហាសុខភាព និងការស្វែងយល់ពីការប្រើប្រាស់អរម៉ូន និងផលប៉ះពាល់នៃការប្រើប្រាស់អរម៉ូនចំនួន ១វគ្គសិក្ខាកាមចំនួន ៤៥នាក់ មកពី១៥គ្លីនិករ៉ាក់ និងបន្តទៅគ្រប់បុគ្គលិក។
  - ចុះធ្វើអភិបាលតាមបែបគាំទ្របានចំនួន ២ដង ខេត្តសៀមរាប។
  - ចូលរួមទិវាប្រយុទ្ធប្រឆាំង និងការរើសអើងអ្នកស្រឡាញ់ភេទដូចគ្នាចំនួន២ដង:
    - រាជធានីភ្នំពេញអ្នកចូលរួមចំនួន៩២នាក់
    - ខេត្តសៀមរាបអ្នកចូលរួមចំនួន៤៥០នាក់
  - ការប្រឹក្សាពីអ័រម៉ូន នៅគ្លីនិក និង Hotspot ចំនួន៦១០
  - ការប្រឹក្សាពី VCCT/HIV នៅគ្លីនិក និងHotspot ចំនួន៦៣៨
  - ការប្រឹក្សាពី RTI/STI នៅគ្លីនិក និង Hotspot ចំនួន៦១៧
  - ការប្រឹក្សាពី Wart (ជំងឺសិរមាន់) នៅគ្លីនិក និងHotspot ចំនួន២៦១
  - ការប្រឹក្សាផ្សេងៗនៅគ្លីនិក និងHotspot ចំនួន៦៥៣

- ការចុះធ្វើ Hotspot ចំនួន៣២៩ដង
- ស្រីស្រស់បានចូលរួមក្នុងការផ្សព្វផ្សាយពីសេវាកម្មគ្លីនិកនៅHotspot ចំនួន៨៣៩នាក់ បានចែកប័ណ្ណបញ្ជូនពេលធ្វើនៅHotspot ចំនួន៩០៣ និងបានចែកខិត្តប័ណ្ណ សៀវភៅ អប់រំចំនួន៨១៨។



ង. បទបង្ហាញពីរបាយការណ៍វឌ្ឍនៈភាពនៃបណ្តាញចតុមុខៈ

- **លទ្ធផលសម្រេចបានសំខាន់ៗសម្រាប់ ២០១៥-២០១៦ :**
  - រៀបចំផែនការសកម្មភាពរយៈពេលមួយឆ្នាំដែលគាំទ្របច្ចេកទេស និងថវិកាដោយអង្គខាណា។
  - សហការជាមួយបណ្តាញហ្វូនប៉ាន ដើម្បីជ្រើសរើសតំណាងបុរសស្រឡាញ់បុរស និងស្រីស្រស់ ក្នុងស្រុកប្រតិបត្តិចំនួន៣៣ស្រុក។
  - ចូលរួមសហការ និងអនុវត្តគម្រោងចាំស្តាត (Jump Start) ជាមួយបណ្តាញអាប់ខម (APCOM) ក្នុងការផ្សព្វផ្សាយស្តីពីព័ត៌មានរបស់បុរសស្រឡាញ់បុរស និងស្រីស្រស់ ក្នុងថ្នាក់តំបន់។
  - ចូលរួមរៀបចំទិវាមោទនភាពអ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជាក្នុងការលើកកម្ពស់សិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា។
  - បានជ្រើសរើសជនបង្គោលចំនួន៣០នាក់ ក្នុង៥ខេត្ត និង១ក្រុង ដូចជាខេត្តសៀមរាប បាត់ដំបង បន្ទាយមានជ័យ ពោធិ៍សាត់ កំពង់ចាម ព្រះសីហនុ និងរាជធានីភ្នំពេញ។
  - រៀបចំកិច្ចប្រជុំប្រចាំត្រីមាសជាមួយគណៈកម្មាធិការប្រតិបត្តិ និងជនបង្គោលរៀងរាល់ត្រីមាសចំនួន៦ដង។
  - ចុះប្រមូលព័ត៌មាន និងសិក្សាករណីរបស់ស្រីស្រស់ ក្នុងខេត្តបាត់ដំបង សៀមរាប និងរាជធានីភ្នំពេញ ព្រមទាំងបញ្ជូនព័ត៌មានបន្តមកដល់ស្ថាប័នពាក់ព័ន្ធ។
  - ចូលរួមរៀបចំ និងសម្របសម្រួលក្នុងការបោះឆ្នោតជ្រើសរើសតំណាងបុរសស្រឡាញ់បុរស និងស្រីស្រស់ ក្នុងមូលនិធិសកល។

- គៀងគរមូលនិធិសង្គ្រោះ និងចុះសួរសុខទុក្ខបុរសស្រឡាញ់បុរស និងស្រីស្រស់ អ្នកស្រឡាញ់ភេទដូចគ្នាដែលរស់នៅជាមួយមេរោគអេដស៍ និងជំងឺអេដស៍ បាន១៥នាក់។
- សួរសុខទុក្ខ និងនាំយកអំណោយជួយដល់ក្រុមប្រឈមមុខខ្ពស់ នៅមណ្ឌលកែប្រែព្រៃស្ពឺ។
- ចុះជ្រើសរើសសមាជិកភាពបានចំនួន៦៥០ រួមមានស្រីស្រស់៣៣០នាក់។
- ធ្វើកិច្ចសហការជាមួយអង្គការឥន្ទនូ ក្នុងការជួយគៀងគររកមូលនិធិសង្គ្រោះជួយដល់ក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ រស់នៅជាមួយមេរោជអេដស៍ និងជំងឺអេដស៍ ដែលក្រលំបាក និងធ្លាក់ខ្លួនឈឺជាទម្ងន់។
- បណ្តាញបានរៀបចំអ្នកប្រឹក្សាយោបល់ ដែលមានការស្មគ្រ័ចិត្តពីអ្នកជំនាញ០២រូប។

▪ មេរៀនទទួលបាន:

- ភាពជាតំណាងរបស់បណ្តាញគឺមានសារៈសំខាន់ណាស់ក្នុងការនាំយកបញ្ហាតម្រូវការ និងការចង់បានរបស់សហគមន៍មកជជែកពិភាក្សាដើម្បីអោយស្ថាប័នថ្នាក់ជាតិនិងអ្នកពាក់ព័ន្ធផ្សេងៗចូលរួមដោះស្រាយ។
- បណ្តាញចតុមុខបានដើរតួនាទីយ៉ាងសំខាន់ ក្នុងការស្វែងរកការគាំទ្រដល់ក្រុមបុរសស្រឡាញ់បុរសនិងស្រីស្រស់ក្នុងការទទួលបានសេវាពេញលេញដូចជាសេវាសុខភាព សេវាសង្គមនានា និងសេវាផ្នែកច្បាប់។
- ទោះបីធនធាននៅមានកម្រិតយ៉ាងណាក៏ដោយការងាររបស់បណ្តាញអាចដំណើការទៅមុខដោយសន្សឹមៗក្នុងការជួយគាំទ្រដល់សហគមន៍ក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់។

## ៤. បញ្ហាប្រឈម៖

- ក្រុមគោលដៅមួយចំនួនបានបង្ករភាពអាណាធិបតី និងគ្មានសណ្តាប់ធ្នាប់នៅតាមទីសាធារណៈដែលធ្វើឲ្យប៉ះពាល់សង្គម។
- កញ្ចប់ថ្លៃធ្វើដំណើរតិចតួចមិនសមនឹងការធ្វើដំណើរជាក់ស្តែងរបស់ក្រុមគោលដៅក្នុងការមកធ្វើPDI និងបើទោះជាមានកម្មវិធីPDI+ នេះក៏ដោយក្រុមគោលដៅមួយចំនួននៅតែមិនខ្វល់ និង មិនមកធ្វើតេស្តឈាមដដែល។
- ក្រុមគោលដៅដែលប្រតិកម្មតេស្តខ្លះនៅតែមិនមកធ្វើតេស្តបញ្ជាក់នៅឡើយ។
- ពុំទាន់បានពង្រីកចំនួនជនបង្គោលរបស់បណ្តាញគ្រប់តំបន់។
- ការចូលរួមក្នុងសង្គមរួមទាំងការស្វែងរកការគាំទ្រមតិនៅមានកម្រិត។
- កន្លែងផ្តល់សេវាសម្រាប់ស្រីស្រស់ ដែលមានភាពរាក់ទាក់មានតិចតួចជាមួយនិងការយល់ដឹងពីចំណេះដឹងលើសុខភាពបន្តពូជ និងសុខភាពផ្លូវភេទនៅមានកម្រិត។

- អ្នកបួរយេនឌ័រមានការបំលាស់ទី និងផ្លាស់ប្តូរដៃគូរួមភេទច្រើន និងមួយចំនួនទៀតមិនទៅ ទទួលសេវា និងមិនទៅតាមការណាត់ ជាពិសេស មិនធ្វើតាមវេជ្ជបញ្ជារបស់គ្រូពេទ្យ។
- ក្រុមគោលដៅខ្លះមិនចង់មកទទួលសេវា (ឈឺខ្លាំងទើបមកទទួលសេវា) ចង់បានតែសេវាឥតគិតថ្លៃ។
- ការមកទទួលសេវានៅមានកម្រិតនៅឡើយ ដោយសារក្រុមគោលដៅមួយចំនួនពេលមានថវិកាបញ្ជូនទើបមកទទួលសេវា។
- អ្នកបួរយេនឌ័រជាបុរសមកទទួលសេវាពិនិត្យសុខភាពមានតិចតួចបំផុត។




- បញ្ហាផ្នែកហិរញ្ញវត្ថុទ្រទ្រង់បណ្តាញក្នុងការអនុវត្តន៍សកម្មភាពឱ្យបានពេញលេញ។
- សមត្ថភាពរបស់គណៈកម្មាធិការប្រតិបត្តិ និងជនបង្គោលនៅមានកម្រិត និងប្រព័ន្ធគ្រប់គ្រង និងការចែកចាយព័ត៌មានទូទៅនៅមានការខ្វះខាត។
- ពុំមានបុគ្គលិកពេញម៉ោងបំរើការងារអោយបណ្តាញថ្នាក់ជាតិ និងកិច្ចសហការជាមួយអង្គការដៃគូជាមួយបណ្តាញមិនទាន់បានល្អប្រសើរ។
- កង្វះខាតយន្តការកសាងសមត្ថភាពដល់ជនបង្គោលតាមបណ្តាខេត្តក្នុងការអនុវត្តន៍ការងាររបស់ខ្លួនឱ្យមានប្រសិទ្ធភាពខ្ពស់។

## ៥. អនុសាសន៍ និងផែនការបន្ទាប់

- បន្តរៀបចំកិច្ចប្រជុំពីរខែម្តងរវាងអាជ្ញាធរមូលដ្ឋាន មន្ទីរសុខាភិបាលខេត្ត អង្គការដៃគូ គ្រួសារអាណាព្យាបាល និងក្រុមស្រីស្រស់ ក្នុងគោលបំណងបង្កើនការសហការគ្នាដើម្បីកាត់បន្ថយការរើសអើង និងមាក់ងាយពីសំណាក់ខ្លួនឯង និងគ្រួសារ ព្រមទាំងជំរុញការអប់រំផ្សព្វផ្សាយដល់ក្រុមគោលដៅទៅទទួលសេវាជាសកល។

- ចុះសួរសុខទុក្ខអ្នករស់នៅជាមួយមេរោគអេដស៍ និងអប់រំបន្តការប្រើប្រាស់ថ្នាំព្យាបាលឲ្យបានទៀងទាត់។
- ពង្រឹងសមត្ថភាពថ្នាក់ដឹកនាំ ឬរៀបចំសិក្ខាសាលាសំរាប់អ្នកដឹកនាំដល់ជនបង្គោល និង គណៈកម្មាធិការបណ្តាញចតុមុខ។
- បង្កើតអោយមានប្រវត្តិរូបរបស់បណ្តាញចតុមុខ ឬប្រវត្តិរូបជាភាសាបរទេស និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអង្គការ និងស្ថាប័នដៃគូពាក់ព័ន្ធ។




- ព្យាយាមពន្យល់ពីផលប្រយោជន៍នៃការមកពិនិត្យសុខភាព និងការធ្វើតេស្តឈាម។
- ត្រូវជំរុញសហការជាមួយអង្គការដៃគូ ក្នុងការបញ្ជូនក្រុមគោលដៅអោយមកទទួលសេវាកាន់តែច្រើន និងជ្រើសរើសអ្នកផ្តល់ប្រឹក្សាជាស្រីស្រស់ ដើម្បីងាយស្រួលក្នុងការទំនាក់ទំនងជាមួយស្រីស្រស់លាក់មុខ។
- ផ្តល់វគ្គបណ្តុះបណ្តាលទៅដល់អ្នកផ្តល់សេវាពីតម្រូវការអ្នកប្តូរយេន៍រ និងផ្សព្វផ្សាយពីសេវាសុខភាពទៅអ្នកប្តូរយេនឌ័រជាបុរស។
- អង្គការជាដៃគូផ្តល់ទិន្នន័យក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ ដល់សមត្ថកិច្ចអាជ្ញាធរមូលដ្ឋាន ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង សន្តិសុខ សណ្តាប់ធ្នាប់សង្គម។
- បន្តការអប់រំ និងផ្សព្វផ្សាយដល់ក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ ពីហានីភ័យនៃការប្រើថ្នាំចាក់ដើម្បីកែសម្ផស្ស និងការប្រើប្រាស់គ្រឿងញៀន ដែលវាប៉ះពាល់ដល់សុខភាពយ៉ាងខ្លាំងទាំងផ្លូវកាយ និងផ្លូវចិត្ត។
- ហិបមូលនិធិសង្គ្រោះស្រីស្រស់ ត្រូវបង្កើតគណៈកម្មាធិការគ្រប់គ្រងថវិកា និងត្រូវសូមការយល់ព្រមពីមន្ទីរធម្មការ និងសាសនា ក្នុងការនាំហិបទៅដាក់តាំងនៅព្រះអង្គធំភ្នំគូលែន និងព្រះអង្គចេកព្រះអង្គចម។ ចំណែកការដាំកូនឈើសម្រេចសូមការឯកភាពដាំក្នុងទីវត្តអារាមវិញ។
- ចំពោះអង្គការដែលធ្វើការជាមួយក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ ដើម្បីអនុវត្តការងារ PDI(+) មានប្រសិទ្ធភាពខ្ពស់ត្រូវមានបណ្តាញច្បាស់លាស់(ម៉ែភូមិ)។